# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 757

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |

៣. ចំណាយគម្រោងសរុប $3,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

RESPONSIBLE UNIT General Department of Information and Communication Technology

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ
បញ្ចកោណទី២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងជួយបង្កើនសមត្ថភាពដល់មន្ត្រីនៃការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រក្នុងការតាមដាន ត្រួតពិនិត្យ និងការពារហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់រាជរដ្ឋាភិបាលពីការគំរាម-កំហែងតាមប្រព័ន្ធអ៊ីនធឺណិត ហើយនឹងត្រៀមបន្តពង្រឹងសមត្ថភាពក្នុងការតាមដានត្រួតពិនិត្យទូទាំងប្រទេស នាពេលអនាគត។ ការទប់ស្កាត់ទាន់ពេលវេលា និង/ឬ ការកាត់បន្ថយការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យានឹងជួយធ្វើឲ្យប្រសើរឡើងលើវិស័យផ្សេងៗទៀត ដែលពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដូចជា រដ្ឋាភិបាលអេឡិកត្រូនិក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក ធនាគារតាមប្រព័ន្ធអេឡិកត្រូនិក ។ល។ លើសពីនេះទៀត គម្រោងនឹងបើកឱកាសជាច្រើនដល់ប្រជាជនកម្ពុជាក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើម្បីសម្រួលដល់ការងារ និងជីវភាពប្រចាំថ្ងៃដោយទំនុកចិត្តខ្ពស់ ហើយថែមទាំងអាចរួមចំណែកដល់ការអភិវឌ្ឍ និងជួយជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាទាំងមូល។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? **មិនគាំទ្រ**

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**ប្រៃសណីយ៍ និងទូរគមនាគមន៍** Information

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**រាជធានីភ្នំពេញ,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

**គម្រោងនេះមានគោលបំណងកសាងសមត្ថភាព និងដាក់ចេញនូវវិធានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។**

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

**ពង្រឹងមុខងាររបស់អង្គភាព/អង្គភាពដែលពាក់ព័ន្ធដូចជា ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ នៃនាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមានគមន៍ និងព័ត៌មាន ដោយដំឡើងឧបករណ៍ ប្រព័ន្ធការពារសុវត្ថិភាព ការពង្រឹងសមត្ថភាពក្នុងការការពារហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសំខាន់ៗរបស់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល តាមរយៈមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។**

**១៥. យុត្តិកម្មលើគម្រោង** ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតត្រូវបានប្រទះឃើញថា
កើតមានឡើងជាញឹកញាប់នាពេលកន្លងមកស្របទៅនឹងការវិវត្តន៍យ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មានដែលនេះជាកត្តាសំខាន់មួយក្នុងការចាត់វិធានការប្រឆាំងនឹងការគំរាមកំហែងផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មានដែលបានកើតមានឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
បានទទួលស្គាល់ថាប្រទេសកម្ពុជាមិនត្រឹមតែជាប្រទេសដែលអាចរងគ្រោះពីការវាយប្រហារប៉ុណ្ណោះទេ
ប៉ុន្តែក៏ជាប្រទេសដែលអាចត្រូវបានគេលួចប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
ដើម្បីវាយប្រហារទៅកាន់ប្រទេសផ្សេងៗផងដែរ។ ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត
បានកើតមានឡើងរួចមកហើយនៅតាមបណ្តាប្រទេសមួយចំនួន ដោយបានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
និងម៉ាស៊ីនកុំព្យូទ័រមេ
ជាក់លាក់ណាមួយមិនអាចដំណើរការបាន លើសពីនេះទៀតយើងអាចសន្និដ្ឋានថាប្រព័ន្ធផ្តល់សេវាសាធារណៈសំខាន់ៗនៅកម្ពុជា
អាចរងការវាយប្រហារ និងលួចគ្រប់គ្រងប្រសិនបើមិនមានយន្តការសន្តិសុខត្រឹមត្រូវ
ដែលអាចនាំមានការវាយប្រហារចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសដទៃទៀត
ស្របពេលដែលប្រទេសកម្ពុជាបាននឹងកំពុងបោះជំហានទៅលើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ម្យ៉ាងវិញទៀតទាំងរដ្ឋាភិបាល
និងប្រព័ន្ធផ្តល់សេវាសាធារណៈសំខាន់ៗនឹងក្លាយជាគោលដៅនៃការវាយប្រហារ
ហេតុដូចនេះគឺមានភាពចាំបាច់ណាស់ក្នុងការបង្កើតរចនាសម្ព័ន្ធកម្រិតជាក់លាក់មួយ និងដាក់ចេញវិធានការណ៍សមស្រប
ដើម្បីប្រឆាំងនឹងការវាយប្រហារដែលអាចធ្វើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមិនដំណើការ
និងការពារការលេចធ្លាយព័ត៌មានសម្ងាត់របស់រដ្ឋាភិបាលផងដែរ។ ដោយផ្អែកលើផែនការមេអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មានឆ្នាំ២០២០ បានដាក់ចេញយ៉ាងច្បាស់លើគម្រោងអាទិភាពចំនួន ៥
ក្នុងនោះការពង្រឹងយន្តការឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័ររបស់ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ
គឺជាគម្រោងអាទិភាពសំខាន់មួយសម្រាប់ត្រៀមខ្លួនជាស្រេចក្នុងការបង្កើតរចនាសម្ព័ន្ធ
ដើម្បីប្រមូលព័ត៌មានទាក់ទងនឹងឧប្បត្តិហេតុសន្តិសុខ
និងដាក់ចេញយកវិធានការសមស្របប្រឆាំងនឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

រាជរដ្ឋាភិបាលកម្ពុជា គ្រប់ក្រសួង-ស្ថាប័ន ប្រជាពលរដ្ឋកម្ពុជា ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត
និងអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតទាំងអស់ក្នុងប្រទេសកម្ពុជា។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គ្មាន

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**កំពុងគាំទ្រ និងលើកកម្ពស់មានការចូលរួមពីស្ត្រី។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**កំពុងស្វែងរកដៃគូវិនិយោគ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងចរចាជាមួយភាគីជប៉ុន និងកូរ៉េ។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| ចំណាយប្រតិបត្តិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 1,534.0 | 733.0 | 733.0 | 3,000.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 254.0 | 253.0 | 253.0 | 760.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 800.0 | 0.0 | 0.0 | 800.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 380.0 | 380.0 | 380.0 | 1,140.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,534.0 | 733.0 | 733.0 | 3,000.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 1,534.0 | 733.0 | 733.0 | 3,000.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: